ប្រិយមិត្តជាទីស្រឡាញ់,

សូមស្វាគមន៍មកក្រុងហ្វីឡាដែលហ្វីយ៉ា ទីក្រុងដែលមានការស្រឡាញ់គ្នាដូចបងប្អូន City of Brotherly Love។ ចាប់តាំងពីការកកើតមក ក្រុងហ្វីឡាដែលហ្វីយ៉ាធ្លាប់ជាកន្លែងមួយទទួលស្វាគមន៍ចំពោះពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់។ ប្រទេសរបស់យើងបានកសាងឡើងដោយជនអន្តោប្រវេសន៍ ហើយភាពរឹងមាំរបស់យើងក្នុងនាមជាទីក្រុង នៅតែបន្តមានការរឹងប៉ឹងដដែលដោយសារមានភាពផ្សេងៗគ្នារបស់យើង។

ក្នុងរយៈពេលជាច្រើនឆ្នាំថ្មីៗនេះ ក្រុងហ្វីឡាដែលហ្វីយ៉ាបានចាប់ផ្តើមចេញមុខជាថ្មីទៀត ជាមជ្ឈមណ្ឌលក្នុងតំបន់មួយមានវប្បធម៌ផ្សេងៗគ្នា ដោយមានប្រជាជនកើនជាលំដាប់ ពិសេសមានប្រជាជនថ្មីដែលតាំងទីលំនៅ មកពីគ្រប់កន្លែងទូទាំងពិភពលោក។ ដោយយោងទៅតាមកម្មវិធីច្បាប់នៃក្រុងធំៗ នៅវិជ្ជាស្ថាន Brookings “ក្នុងចំណោមតំបន់ប្រហាក់ប្រហែលគ្នា មហាក្រុងហ្វីឡាដែលហ្វីយ៉ា មានប្រជាជនអន្តោប្រវេសន៍ច្រើន និងកើនចំនួនឡើងយ៉ាងឆាប់រហ័ស ដែលសព្វថ្ងៃ នេះមានចំនួនលើសពី 500,000 ទៅហើយ បើគិតទៅគឺមានចំនួន៩ភាគរយនៃ 9% នៃប្រជាជនទាំងអស់។ ”

នៅពេលដែលយើងកំពុងដុះដាលរបៀបជាក្រុងនេះ គឺជាការសំខាន់ណាស់ដែលប្រជាជនទាំងអស់អាចទទួលសេវាកម្មនានា ពីទីក្រុងដោយគ្មានការរារាំង។ អង្គការ Global-Philadelphia បំរើក្នុងនាមបង្រួបបង្រួមដើម្បីពង្រឹងទំនាក់ទំនងរវាងសហគមន៍ដែលមានភាសាសាស្រ្តផ្សេងៗខុសៗគ្នានិងទីក្រុងរបស់យើង ដោយធ្វើឲ្យមានការប្រសើរឡើងក្នុងការទទួលសេវាកម្មផ្នែកភាសានៃក្រុងភីឡាដែលហ្វីយ៉ា។ សមាជិកម្នាក់ៗនៃទីក្រុងនេះសមនឹងមានសំឡេងត្រូវគេដឹងឮ ហើយអង្គការ Global-Philadelphia ធានាថាប្រជាជនទាំងអស់ដែលនិយាយភាសាអង់គ្លេសមិនបានល្អ គឺត្រូវមានសំឡេងគេដឹងឮដែរ។

ក្នុងនាមជាចៅហ្វាយក្រុង ខ្ញុំបានប្តេជ្ញាថាសម្លេងប្រជាជនទាំងអស់ត្រូវតែបានឮនិងបានយល់ ដោយមិនគិតថាចេះភាសាមិនស្ទាត់នោះទេ។ ទីក្រុងនឹងបន្តធ្វើឲ្យប្រសើរឡើងនូវ ការរួបរួមនិងការបញ្ចូលអ្នកមកតាំងទី លំនៅថ្មី នូវអ្នកមិនចេះភាសា និងវប្បធម៌នៃជនភាគតិច ទៅក្នុងមហាគ្រឹះសង្គមនិងសេដ្ឋកិច្ចនៃទីក្រុង។ ខ្ញុំមានសេចក្តីរីករាយ និងធ្វើយ៉ាងណាបន្តការខំប្រឹងប្រែងរបស់យើងធ្វើឲ្យក្រុងហ្វីឡាដែលហ្វីយ៉ា ទៅជាចំណុចគោលដៅអន្តរៈជាតិដ៏សំខាន់មួយ។

ដោយក្តីស្មោះស្ម័គ្រ
Michael A. Nutter
ចៅហ្វាយក្រុងហ្វីឡាដែលហ្វីយ៉ា